# Living the Lotus 12

## Buddhism in Everyday Life

2024
VOL. 231




## Overseas Members of Rissho Kosei-kai Participate in the 2024 Oeshiki-Ichijo Festival in Tokyo

Living the Lotus
Vol. 231 (December 2024)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President’s Message*

# ជំនួបដែលចិញ្ចឹមចិត្តគោរព និងសេចក្ដីខ្មាសអៀន ②

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## បង្កើតជំនួបដោយបង្រៀនព្រះធម៌ព្រះសម្មាសម្ពុទ្ធ

ព្រះគ្រូសៃង្យោដែលជាព្រះសង្ឃនិងជាកវីនៅជំនាន់ហេយ៉ានបានសរសេរកំណាព្យមួយ។ ”បើយើងប្រ មូលតំណក់ទឹកសន្សើមដែលដក់លើស្លឹករុក្ខជាតិនានានៅក្នុងវាលនារដូវលំហើយ នឹងបានជាស្រះបោក្ខរណី” កំណាព្យនេះពណ៌នាពីទិដ្ឋភាពដ៏វិចិត្រដែលបង្ហាញពីស្លឹកឈើដែលឡើងពណ៌លឿងក្រហ មហើយទទឹកដោយទឹកសន្សើមពេលព្រហាមនៅចុងរដូវលំហើយជិតចូលរដូវរងា ។តាមធម្មតាទឹកសន្សើ មពេលព្រឹកគឺជានិមិត្តរូបនៃអ្វីដែលមានតែមួយប៉ប្រិចប៉ុណ្ណោះនឹងរលប់បាត់ទៅវិញយ៉ាងឆាប់ តែព្រះគ្រូសៃង្យោបានសរសេរថាប្រសិនបើគេប្រមូលតំណក់ទឹកសន្សើមនោះវានឹងក្លាយទៅជាស្រះឈូកទឹកសន្សើមដ៏ថ្លាឆ្វង់ពេញព្រៀប។ មើលតែមួយឆ្វាច់ឃើញហាក់បីដូចជាកំណាព្យដែលពណ៌នាអំពីអច្ឆរិយៈនៃធម្មជាតិ ក៏ប៉ុន្តែកំណាព្យនេះវាត្រួតលើឃ្លាព្រះធម៌ក្នុងវគ្គមួយនៅក្នុងជំពូកព្រះរាជធានីនិមិត្តនៃគម្ពីរព្រះបទុមសូត្រ “សេចក្ដីប្រាថ្នារបស់ខ្ញុំព្រះករុណាអាត្មាភាពគឺសុំឱ្យកុសលផលបុណ្យនេះបានផ្សព្វផ្សាយដល់មនុស្សគ្រប់រូបហើយយើងទាំងអស់គ្នានឹងអាចដើរលើមាគ៌ាព្រះពុទ្ធសាសនាជាមួយគ្នា”។ ទឹកសន្សើមគឺជានិមិត្តរូបនៃធាតុជាព្រះពុទ្ធ។

នៅចុងបញ្ចប់អ្វីដែលយើងអាចធ្វើបានគឺមានតែយើងម្នាក់ៗ ចាប់ភ្លឹកពីធាតុជាព្រះពុទ្ធរបស់ខ្លួនឯង ហើយខិតខំបង្កើតពិភពលោកដែលមនុស្សគ្រប់គ្នាគោរពអ្នកដទៃ និងរស់នៅដោយសុខដុមរមនាជិតស្និទ្ធនិងប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានទុក្ខ។ បើនិយាយឱ្យងាយយល់ គឺថាបច្ចុប្បន្នកាលនេះជំនួបតាមរយៈការផ្សព្វផ្សាយសាសនាត្រូវការច្រើនជាងពេលណាៗទាំងអស់។

## ស្រះបោក្ខរណីដែលបំភ្លឺដោយធាតុជាព្រះពុទ្ធ

នៅក្នុងលេខមុនខ្ញុំព្រះករុណាអាត្មាភាពបានសរសេរថា នៅពេលដែលស្មារតីនៃការគោរពកើតឡើងសេចក្តីអៀនខ្មាសក៏កើតឡើងដោយធម្មជាតិ,ខ្ញុំព្រះករុណាអាត្មាភាពនេះក៏ធ្លាប់មានបទពិសោធន៍ជំជូរចត់ ប៉ុន្តែគួរឱ្យដឹងគុណដែលនាំឱ្យខ្ញុំព្រះករុណាអាត្មាភាពបានរៀនសូត្រអំពី "សេចក្តីគោរពនិងភាពអៀនខ្មាស" ដោយមិនបានរំពឹងទុក។

នៅរដូវក្តៅមួយ។កាលនោះខ្ញុំព្រះករុណាអាត្មាភាពជានិស្សិតឆ្នាំទីបីនៃសាកលវិទ្យាល័យ។នៅពេលនោះខ្ញុំព្រះករុណាអាត្មាភាពចំណាយពេលពីរខែដើម្បីធ្វើការហ្វឹកហាត់មាគ៌ាកាប់ដាវ（Kendo）នៅ កន្លែងហ្វឹកហាត់(Kendo dojo)(និងនៅផ្ទះលោកគ្រូ)។ការមកហាត់ហ្វឹកហ្វឺននេះគ្មានអ្នកណាគេបង្ខិតបង្ខំទេគឺយើងមកដោយស្ម័គ្រចិត្តហើយថែមទាំងត្រូវដាក់ពាក្យសុំចូលរួបរួមជាមុនទៅទៀត។តែទោះបីជាដូច្នេះក៏ដោយក៏ដោយសារតែហាត់នឿយនឹងការហ្វឹក ហ្វឺនដ៏តឹងរ៉ឹងនិងការបោសជូតសម្អាតព្រមទាំងការ ងារផ្សេងៗទៀតខ្ញុំព្រះករុណាអាត្មាភាពមិនអាចទ្រាំទ្របានក៏លួចរត់ចេញទៅផ្ទះវិញឈប់ហ្វឹកហាត់កណ្តាលទី។នៅថ្ងៃបន្ទាប់លោកគ្រូរបស់ខ្ញុំណាកាមូរ៉ា តូគីជី（Tokichi Nakamura）បានមកផ្ទះរបស់ខ្ញុំ ហើយស្រែកឡូឡាពូពេញផ្ទះថា "ឯងឥឡូវជាកូនរបស់យើង។មក!មកផ្ទះវិញ" ហើយគាត់បានយកខ្ញុំព្រះករុណាអាត្មាភាពត្រឡប់ទៅកន្លែងហាត់ដែលគេហៅថាដូជោវិញ។ពេលនោះខ្ញុំព្រះករុណាអាត្មាភាពចាំបានថាមានចិត្តក្តៅក្រហាយនឹងលោកគ្រូហើយចង់មានះប្រឆាំងនឹងលោកជាខ្លាំងនៅពេលដែលទទួលការស្តីបន្ទោសដ៏ធ្ងន់ធ្ងរពីគាត់។នៅពេលដែលយើងគ្មានគំនិតចង់អភិវឌ្ឍខ្លួនយើងៗមិនធ្វើស្វ័យត្រិះរិះមុនទេផ្ទុយទៅវិញមនោសញ្ចេតនាកំហឹងបានផុសចេញមកមុនដូច្នេះទើបបានជាយើងមិនមានការខ្មាសអៀននោះ។

ក៏ប៉ុន្តែចិត្តក្តៅក្រហាយនោះវាបានទៅជាកម្លាំងទាញឱ្យខ្ញុំព្រះករុណាអាត្មាភាពចង់ងើបឡើងហើយចង់លូតលាស់ដោយគិតថាមិនត្រូវនៅតូចតឿបែបនេះរហូតទេ។ដូចគ្នានឹងធាតុជាព្រះពុទ្ធដែរគឺថាភាពអៀនខ្មាសដែលនៅក្នុងខ្លួនយើងបានចាប់ផ្តើមកម្រើក។បើនិយាយពីខ្ញុំព្រះករុណាអាត្មាភាពវិញគឺថាខ្ញុំព្រះករុណាអាត្មាភាពបានធ្វើការសារភាពកំហុសឬក៏ថាបានកែប្រែគំនិតដោយខិតខំធ្វើយ៉ាងណាឱ្យគេជឿទុកចិត្តខ្លួនវិញ។

ដូចគ្នានឹងនេះដែរ,ការសារភាពកំហុសនៅក្នុងជំនឿឬសាសនាក៏ជាចំណុចសំខាន់មួយនៅពេលដែលយើងគិតអំពីការចម្រើនលូតលាស់របស់មនុស្ស។

តាមរយៈអន្តរកម្មនៃការជួបគ្នា សេចក្តីគោរពនិងភាពអៀនខ្មាសត្រូវបានដាស់ឱ្យភ្ញាក់។ ការបង្រៀន និងការណែនាំកិច្ចប្រតិបត្តិមាគ៌ាព្រះពុទ្ធសាសនានៅក្នុងសមាគមរីស្ស៊ូកូសេកៃរបស់យើងក៏មានអត្ថន័យសំខាន់ចំពោះការចិញ្ចឹមបីបាច់ស្មារតីបែបនេះនៅក្នុងខ្លួនៗឯងនិងអ្នកដទៃដែរ។ ទោះបីជាយើងនៅមានក្តីបារម្ភពីការរីករាលដាលនៃជំងឺឆ្លងកូវីដនៅឡើយក៏ដោយប្រសិនបើមានមនុស្សដែលនៅក្បែរខ្លួនយើងមានក្តីព្រួយបារម្ភឬមានបញ្ហាយើងហុចដៃទៅគេហើយយើងនឹងប្រើឱកាសជួបគ្នាទាំងនេះឱ្យទៅជាឱកាសដើម្បីពង្រីកចំណងនិស្ស័យពុទ្ធសាសនារបស់យើងហើយសហគមន៍មូលដ្ឋានក៏នឹងទៅជាស្រះឈូកមួយដ៏ភ្លឺដែលធាតុជាព្រះពុទ្ធចែងចាំងយ៉ាងចិញ្ចាចចិញ្ចែងជាទីកន្លែងប្រកបទៅដោយសេចក្តីសុខ។នេះជាតួនាទីរបស់យើងទាំងអស់គ្នា។ ដើម្បីធានាថាយើងមិនភ្លេចរឿងនេះយើងអានឬសូត្រព្រះធម៌ខាងលើឱ្យចងចាំក្នុងចិត្តរត់មាត់បូជាចំពោះព្រះពុទ្ធនៅពេលសូត្រធម៌ប្រចាំថ្ងៃរបស់យើង ហើយប្តេជ្ញាថា "យើងនឹងកសាងពិភពលោកមួយដែលមនុស្សគ្រប់គ្នាអាចភ្ញាក់រលឹកពីធាតុជាព្រះពុទ្ធរបស់ពួកគេហើយមានអារម្មណ៍សប្បាយរីករាយ" ។

ជាជំហានដំបូងគឺយើងចុះទៅសួរសុខទុក្ខនិងផ្តល់សមានចិត្តនៅតាមផ្ទះនីមួយៗឬកន្លែងធ្វើការនិងសហគមន៍។ ឥឡូវក្រឡេកទៅមើលឆ្នាំមុនវិញតើខ្លួនអ្នកពីឆ្នាំមុនជាខ្លួនដូចម្តេច?



『កូសេ』 លេខខែ១២ឆ្នាំ ២០២៤




# A Global Buddhist Movement




## Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp